# សេវាថែទាំសត្វនៅទីក្រុងឡុងប៊ិច

**សត្វសម្រាប់យកទៅចិញ្ចឹម**

សត្វរបស់យើងក៏មានបង្ហាញលើគេហទំព័រ ៖

- [www.shelterme.com/LongBeach](www.shelterme.com/LongBeach)
- [www.facebook.com/LongBeachAnimalCare](www.facebook.com/LongBeachAnimalCare)
- [www.longbeach.petfinder.com](www.longbeach.petfinder.com)

អ្នកក៏អាចទាញយកកម្មវិធីទូរស័ព្ទនៃសេវាថែទាំសត្វនៅទីក្រុងឡុងប៊ិចរបស់យើង ដែលអាចរកបានក្នុងហាងលក់កម្មវិធីរបស់ Google ឬ iTunes ដោយប្រើតំណភ្ជាប់នេះ ៖http://getmyapp.me/LBACS/

**ព័ត៌មានអំពីការយកទៅចិញ្ចឹម**

នៅភូមិនេះ សត្វដែលមានគឺអាចយកទៅចិញ្ចឹមតាមរយៈ spcaLA។ សូមចូលទៅកាន់ spcaLAសម្រាប់ការរៀបរាប់ទាំងស្រុងអំពីលក្ខខណ្ឌ និងថ្លៃសេវាយកសត្វទៅចិញ្ចឹម។ សត្វដែលអាចយកទៅចិញ្ចឹមច្រើនទៀត ៖ spcaLA

ថ្លៃសេវាយកសត្វទៅចិញ្ចឹម រួមមាន ៖

• ការក្រៀវ/ក្រៀវ (ឆ្កែ ឆ្មា និងទន្សាយ)
• ការប្រើថ្នាំបំបាត់អាការឈឺចុកចាប់ (ទន្សាយតែប៉ុណ្ណោះ)
• មីក្រូឈីព/ការចាក់ថ្នាំបង្ការបច្ចុប្បន្នដែលសមស្របនឹងពូជសត្វ (មិនរាប់បញ្ចូលការចុះឈ្មោះ)
• ការពិនិត្យសុខភាព
• លិខិតបញ្ជាក់សម្រាប់ការពិនិត្យសុខភាពឥតគិតថ្លៃ
• ការផ្តល់ជូនពិសេសសម្រាប់ការធានារ៉ាប់រងសត្វចិញ្ចឹម
• ប្រឡៅម៉ាក spcaLA*
• ខ្សែចងម៉ាក spcaLA (ឆ្កែតែប៉ុណ្ណោះ)*
• កញ្ចប់រង្វាន់សម្រាប់ការយកសត្វទៅចិញ្ចឹមដែលមានការបញ្ចុះតម្លៃ និងការផ្តល់ជូននូវថ្នាក់ហ្វឹកហាត់ឆ្កែ spcaLA ទីផ្សារ spcaLA និងសណ្ឋាគារសត្វចិញ្ចឹម spcaLA & ការសម្អាតថែទាំសត្វចិញ្ចឹម

**ជម្រករបស់យើង**

គេហទំព័ររបស់យើងបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានទាក់ទងនឹងសត្វដែលអាចយកទៅចិញ្ចឹម។ រូបថត និង/ឬសេចក្តីពណ៌នាអំពីសត្វរបស់យើងត្រូវបានបញ្ចូល និងលុបចេញនៅពេលសត្វត្រូវបានយកទៅចិញ្ចឹម ឬត្រូវបានប្រគល់ជូនម្ចាស់ដើមរបស់វាវិញ ។ល។ សត្វដែលមានបង្ហាញលើគេហទំព័ររបស់យើងគឺអាចរកបានសម្រាប់ការយកទៅចិញ្ចឹមចំពោះអ្នកដែលមកស្នើសុំយកទៅចិញ្ចឹមមុនគេ។ ដោយសារការបង្កាត់ពូជចម្រុះ ព័ត៌មាននៃសេចក្តីពណ៌នាអាចខុសពីរូបថត។ ទោះបីជាយើងប្រឹងប្រែងរក្សាការធ្វើបច្ចុប្បន្នភាពនៃព័ត៌មាននៅលើគេហទំព័ររបស់យើងក្តី យើងមិនអាចធានាថាសត្វដែលមាននៅលើទំព័រទាំងនេះនឹងអាចរកបាន នៅពេលអ្នកមកដល់មជ្ឈមណ្ឌលថែទាំសត្វដើម្បីយកសត្វទៅចិញ្ចឹមនោះទេ។ សេវាថែទាំសត្វនៅទីក្រុងឡុងប៊ិចមិនផ្តល់ការកក់ទុកសត្វសម្រាប់ការយកទៅចិញ្ចឹមតាមរយៈការហៅទូរស័ព្ទ ឬ អ៊ីមែលទេ។ អ្នកត្រូវមកដល់មជ្ឈមណ្ឌលដើម្បីយកសត្វទៅចិញ្ចឹម និងប្រាប់លេខអត្តសញ្ញាណរបស់សត្វ (ចាប់ផ្តើមពីអក្សរ A) នៅពេលសួរនាំអំពីសត្វចិញ្ចឹមជាក់លាក់ណាមួយ ។

សម្គាល់ ៖ ច្បាប់នៃរដ្ឋកាលីហ្វ័រញ៉ាចែងថា សត្វឆ្កែ និងសត្វឆ្មាដែលយកទៅចិញ្ចឹមទាំងអស់ត្រូវក្រៀវ ឬ ក្រៀវ មុនពេលចេញពីជម្រករបស់យើង។